(១៨)

# សារាចរណែនាំស្តីពី

# ការបង់ប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន

# និងសំណែសចំណាយ

លេខៈ ០០៩ សហវ

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ០០៥.....សហវ

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥

## សារាចរណែនាំ

## ស្តីពី

## ការបង់ប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងសំណល់ចំណាយ

ដើម្បីបង្កើនប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋទេយ្យបុរេប្រទាន បុរេប្រទាននិងសំណល់ចំណាយ និងក្នុងស្មារតីទទួលខុសត្រូវលើការទូទាត់ជម្រះប្រាក់នៅសល់ដែលត្រូវបង់ចូលរតនាគារវិញ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដូចតទៅ÷

១. ការបង់ប្រាក់បុរេប្រទាននៅសល់

១.១. ក្នុងករណីមានការបង់ប្រាក់ចូលរតនាគារ (គណនីរបស់រតនាគារនៅធនាគារ) ដើម្បីទូទាត់ជម្រះបុរេប្រទាន ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រគល់ជូនរតនាគារនូវ÷

-លិខិតស្នើសុំបង់ប្រាក់ទូទាត់ជម្រះបុរេប្រទាន ដោយមានការបញ្ជាក់ចំនួនទឹកប្រាក់សល់តាមជំពូក គណនី អនុគណនី ចំនួន ០១ច្បាប់

- អត្ថន័យនៃការបង់ប្រាក់គឺ÷ទូទាត់ជម្រះបុរេប្រទានដែលបានទទួលពីរតនាគារនៅថ្ងៃទី...ខែ...ឆ្នាំ..
- យោងលិខិតអនុញ្ញាតផ្តល់បុរេប្រទានលេខ......សហវ ចុះថ្ងៃទី...ខែ...ឆ្នាំ.....

-បណ្ណបង់ប្រាក់ឬ ប្រកាសឥណទានរបស់ធនាគារ ចំនួន ០១ច្បាប់។

១.២. ការបង់ប្រាក់នេះមិនមែនជាប្រតិបត្តិការបង់ចូលថវិកានិងពុំតម្រូវឱ្យមានសលាកប័ត្របង់ចំណូលថវិកាទេ។

១.៣. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ÷

ឥណពន្ធ គណនី ធនាគារ/បេឡា (លេខ ១១០១/១១០៥/១១០៦/១៣០១)

ឥណទាន គណនី បុរេប្រទាន (លេខ ១៥០៥១/១៥០៥២/១៥០៥៦)។

២. ការបង់ប្រាក់រដ្ឋទេយ្យបុរេប្រទាននៅសល់

២.១. ក្នុងករណីមានការបង់ប្រាក់ចូលរតនាគារ (គណនីរបស់រតនាគារនៅធនាគារ) នូវប្រាក់រដ្ឋទេយ្យបុរេប្រទានសល់ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រគល់ជូនរតនាគារនូវ÷

-លិខិតស្នើសុំបង់ប្រាក់ទូទាត់ជម្រះរដ្ឋទេយ្យបុរេប្រទាន ចំនួន ០១ច្បាប់

- អត្ថន័យនៃការបង់ប្រាក់គឺ÷ បង់ប្រាក់ទូទាត់ជម្រះរដ្ឋទេយ្យបុរេប្រទាន

-បណ្ណបង់ប្រាក់ឬប្រកាសឥណទានរបស់ធនាគារចំនួន ០១ច្បាប់។

២.២. ការបង់ប្រាក់នេះមិនមែនជាប្រតិបត្តិការបង់ចូលថវិកានិងពុំតម្រូវឱ្យមានសលាកប័ត្របង់ចំណូលថវិកាទេ។

២.៣. កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ÷

ឥណពន្ធ គណនី ធនាគារ/បេឡា (លេខ ១១០១/១១០៥/១១០៦/១៣០១)

ឥណទាន គណនី រដ្ឋទេយ្យបុរេប្រទាន (លេខ ១៤០១/១៤០២)។

៣.ការបង់សំណៃសចំណាយ

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិ បានទទួលប្រាក់ពីរតនាគារតាមរយៈ អាណត្តិបើកប្រាក់ ហើយត្រូវបង់ប្រាក់សល់ពីចំណាយចូលរតនាគារវិញ ហៅថា ការបង់សំណៃសចំណាយ។ ការបង់សំណៃសចំណាយ ត្រូវអនុវត្តតាមនីតិវិធីមានដូចខាងក្រោម÷

៣.១.ការបង់សំណៃសចំណាយនៅក្នុងឆ្នាំ(បង់នៅក្នុងឆ្នាំដែលបានបោះផ្សាយអាណត្តិបើកប្រាក់)÷

៣.១.១.ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រគល់ជូនរតនាគារនូវ÷

- លិខិតស្នើសុំបង់សំណៃសចំណាយ ដោយបញ្ជាក់ចំនួនទឹកប្រាក់សល់តាមជំពូក គណនី អនុគណនី ចំនួន ០១ច្បាប់
- បណ្ណបង់ប្រាក់ឬប្រកាសឥណទានរបស់ធនាគារចំនួន ០១ច្បាប់
- សលាកប័ត្របង់សំណៃសចំណាយចំនួន ០៣ច្បាប់ (មិនមែនជាសលាកប័ត្របង់ចំណូលថវិកាទេ)។ សលាកប័ត្របង់សំណៃសចំណាយត្រូវវាយលម្អិតតាមជំពូក គណនី អនុគណនី ដែលពាក់ព័ន្ធនឹងចំណាយថវិកានូវចំនួនទឹកប្រាក់ ដែលត្រូវបង់ដើម្បីបន្ថយបន្ទុកចំណាយថវិកានិងបង្កើនឥណទានឡើងវិញ។

៣.១.២.កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ÷

ឥណពន្ធ គណនី ធនាគារ/បេឡា(លេខ ១១០១/១១០៥/១១០៦/១៣០១)

ឥណទាន គណនី ចំណាយថវិកា(លេខ៦...)។

៣.២.ការបង់សំណៃសចំណាយឆ្លងឆ្នាំ(ការបង់ប្រាក់នៅក្នុងឆ្នាំបន្ទាប់នៃការបោះផ្សាយអាណត្តិបើកប្រាក់)

៣.២.១.ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រគល់ជូនរតនាគារនូវ÷

- លិខិតស្នើសុំបង់សំណៃសចំណាយ ចំនួន ០១ច្បាប់
- បណ្ណបង់ប្រាក់ឬប្រកាសឥណទានរបស់ធនាគារ ចំនួន ០១ច្បាប់
- សលាកប័ត្របង់ចំណូលថវិកាពីសំណៃសចំណាយ ចំនួន ០៤ច្បាប់។

៣.២.២.កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ÷

ឥណពន្ធ គណនី ធនាគារ/បេឡា(លេខ ១១០១/១១០៥/១១០៦/១៣០១)

ឥណទាន គណនី ផលហិរញ្ញវត្ថុផ្សេងៗ(លេខ ៧៦៩៨)។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមលើស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល សហការអនុវត្តសារាចរណែនាំនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ*
- *គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
- *គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន មន្ទីរ ..................

អង្គភាព.............

លេខ...

| | |
|---|---|
| លេខសំគាល់ | : |
| លេខគណនីឥណពន្ធ | : |
| លេខគណនីឥណទាន | : |

# សលាកបត្របង់សំណែសចំណាយ

(ក្នុងឆ្នាំ)

-ឈ្មោះនិងអាស័យដ្ឋាននៃអង្គភាពគ្រប់គ្រង៖ ...............

-ឈ្មោះនិងអាស័យដ្ឋាននៃអង្គភាពបង់សំណែសចំណាយ៖ ...............

-ស្នើធនាគារកណ្តាល កាត់ត្រាបន្ថយទឹកប្រាក់ចំណាយថវិកានៅក្នុង ជំពូក គណនី អនុគណនី ដូចខាងក្រោម៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| សរុប | | | | | | |

-សរុបទឹកប្រាក់ជាអក្សរ៖ (........................)

ធ្វើនៅ..........ថ្ងៃទី.....ខែ.........ឆ្នាំ.........

ធ្វើនៅ.......... ថ្ងៃទី..... ខែ..... ឆ្នាំ២០១៨

អគ្គនាយក ប្រធាននាយកដ្ឋាន អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ

អគ្គនាយកដ្ឋានធនាគារជាតិ ចំណូលនិងចំណាយថវិកា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន មន្ទីរ ..................

អង្គភាព..................

លេខ............

| | |
|---|---|
| លេខសំគាល់ | : |
| លេខគណនីឥណពន្ធ | : |
| លេខគណនីឥណទាន | : |

# សលាកប័ត្របង់សំណល់ចំណាយចូលថវិកា

(បង់ឆ្លងឆ្នាំ)

-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពគ្រប់គ្រង៖ ...............

-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពបង់សំណល់ចំណាយចូលថវិកា៖ ...............

-ស្នើរតនាគាររាជធានី ខេត្ត កត់ត្រាជាចំណូលថវិកានៅក្នុង ជំពូក គណនី អនុគណនី ដូចខាងក្រោម៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| សរុប | | | | | | |

-សរុបទឹកប្រាក់ជាអក្សរ៖ (.........................)

ធ្វើនៅ..........ថ្ងៃទី.....ខែ.........ឆ្នាំ.........

ធ្វើនៅ......... ថ្ងៃទី..... ខែ..... ឆ្នាំ២០១៨

ប្រធានរតនាគារខេត្ត.... ប្រធានការិយាល័យគណនេយ្យ.... អ្នកពិនិត្យ គណនេយ្យករ

ប្រធានអង្គភាព ប្រធានគណនេយ្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន បន្ទុក ..................

អង្គភាព.............

លេខ...

| | |
|---|---|
| លេខសំគាល់ | : |
| លេខគណនីឥណពន្ធ | : |
| លេខគណនីឥណទាន | : |

# សលាកប័ត្របង់សំណែសចំណាយ

(ក្នុងឆ្នាំ)

-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពគ្រប់គ្រង៖ ...............

-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពបង់សំណែសចំណាយ៖ ...............

-ស្នើរធនាគាររាជធានី ខេត្ត កាត់ត្រាបន្ថយទឹកប្រាក់ចំណាយថវិកានៅក្នុង ជំពូក គណនី អនុគណនី ដូចខាងក្រោម៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| សរុប | | | | | | |

-សរុបទឹកប្រាក់ជាអក្សរ៖ (.........................)

ធ្វើនៅ..........ថ្ងៃទី.....ខែ.........ឆ្នាំ.........

ធ្វើនៅ.......... ថ្ងៃទី..... ខែ..... ឆ្នាំ២០១៥

ប្រធានធនាគារខេត្ត.... ប្រធានការិយាល័យគណនេយ្យ.... អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន មន្ទីរ ..................

អង្គភាព..................

លេខ............

| | |
|---|---|
| លេខសំគាល់ | : |
| លេខគណនីឥណពន្ធ | : |
| លេខគណនីឥណទាន | : |

# សលាកបត្របង់សំណែសចំណាយចូលថវិកា

(បង់ឆ្លងឆ្នាំ)

-ឈ្មោះនិងអាស័យដ្ឋាននៃអង្គភាពគ្រប់គ្រង៖ ...............

-ឈ្មោះនិងអាស័យដ្ឋាននៃអង្គភាពបង់សំណែសចំណាយចូលថវិកា៖ ...............

-ស្នើរតនាគារកណ្តាល កត់ត្រាជាចំណូលថវិកានៅក្នុង ជំពូក គណនី អនុគណនី ដូចខាងក្រោម៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| សរុប | | | | | | |

-សរុបទឹកប្រាក់ជាអក្សរ (........................)

ធ្វើនៅ...........ថ្ងៃទី.....ខែ.........ឆ្នាំ......

ធ្វើនៅ......... ថ្ងៃទី..... ខែ..... ឆ្នាំ២០១៥

អគ្គនាយក ប្រធាននាយកដ្ឋាន អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ

អគ្គនាយកដ្ឋានរតនាគារជាតិ ចំណូលនិងចំណាយថវិកា